អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ប្រទេសកម្ពុជា បានក្លាយជាប្រទេសផលិតរ៉ែមាសមួយ ក្នុងចំណោមប្រទេសផលិតរ៉ែមាសពិភពលោក
- CDC អនុម័តគម្រោងវិនិយោគរោងចក្រកាត់ដេរចំនួន៣ មានតម្លៃជិត ១៥លានដុល្លារ
- ទីផ្សារជ័រកៅស៊ូ នឹងអាចមានស្ថិរភាពល្អ ខណៈកម្ពុជា នឹងមានរោងចក្រផលិតសំបកកង់រថយន្ត
- កម្ពុជា នឹងបង្កើនការនាំចេញគ្រាប់ស្វាយចន្ទីទៅកាន់ទីផ្សារអឺរ៉ុប អាមេរិក កាណាដា ចិន និងអូស្ត្រាលី
- ថវិកាសារពើពន្ធរយៈពេលមធ្យមរបស់ប្រទេសហ្វីលីពីន ឆ្នាំ២០២១-២០២៤
- ទំនាក់ទំនងរវាងអាស៊ាន និងចិន លើកម្ពស់គុណតម្លៃអាស៊ី
- វៀតណាម បង្កើតគោលនយោបាយថ្មី ដើម្បីលើកទឹកចិត្តដល់ការវិនិយោគលើវិស័យកសិកម្ម
- ធនាគារសហព័ន្ធ(US Fed) នឹងនៅតែរក្សាជំហរលើគោលនយោបាយរបស់ខ្លួន ថ្វីបើមានការកើនឡើងនៃអតិផរណា
- សេដ្ឋកិច្ចបារាំង នឹងមានកំណើនខ្ពស់ជាងការរំពឹងទុក នៅឆ្នាំ២០២១
- កម្ពុជារំពឹងថា នឹងចរចាជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) ឆាប់ៗនេះ
- ពាណិជ្ជកម្មចិន-រុស្ស៊ី នឹងកើនដល់២០០ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២៤


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជា បានក្លាយជាប្រទេសផលិតរ៉ែមាសមួយ ក្នុងចំណោមប្រទេសផលិតរ៉ែមាសពិភពលោក



*ប្រភព៖ postkhmer, 2021 រូបភាព៖ Renaissance Minerals*

បន្ទាប់ពីរាជរដ្ឋាភិបាល បានប្រកាសដាក់ឱ្យដំណើរការការដ្ឋានអាជីវកម្ម និងរោងចក្រចម្រាញ់រ៉ែមាសជាលក្ខណៈឧស្សាហកម្មជាលើកដំបូង នៅតំបន់អូរខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ប្រទេសកម្ពុជាបានក្លាយខ្លួនទៅជាប្រទេសផលិតរ៉ែមាសមួយ ក្នុងចំណោមប្រទេសផលិតរ៉ែមាសពិភពលោក។

ការដាក់ឱ្យដំណើរការអាជីវកម្មនេះធ្វើឡើង បន្ទាប់ពីក្រុមហ៊ុន Renaissance Minerals (Cambodia) Limited ដែលជាក្រុមហ៊ុនអូស្ត្រាលីទី១ បានធ្វើការសិក្សាស្រាវជ្រាវស្វែងរុករកអស់រយៈពេល១៤ ឆ្នាំ។ ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន Renaissance Minerals ដែលមានលក្ខណៈជាស្តង់ដាអន្តរជាតិនេះ អាចផលិតជាមាសដុំពាក់កណ្តាលសម្រេចក្នុងអត្រាមាស៩០% ក្នុងរយៈពេលមួយថ្ងៃ។ បន្ថែមពីនេះ ក្រុមហ៊ុនមានលទ្ធភាពផលិតមាសសុទ្ធបានប្រមាណជា ៣ តោនក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៨ឆ្នាំដំបូង។

ប្រទេសកម្ពុជារំពឹងថា ការផលិតមាសជាលក្ខណៈឧស្សាហកម្មពីជម្រករ៉ែតំបន់អូរខ្វាវ នឹងផ្តល់ប្រយោជន៍ចំណូលដុលជាមធ្យមប្រមាណ១៨៥ លានដុល្លារ ក្នុង ១ ឆ្នាំ។ បន្ថែមពីនេះ ចំណូលថវិកាជាតិពីសួយសារ និងសារពើពន្ធផ្សេងៗមានជាមធ្យម ៤០ លានដុល្លារ ក្នុង ១ ឆ្នាំ។ ថវិកាទាំងនេះនឹងត្រូវយកមកប្រើក្នុងចរន្តថវិកាជាតិ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។

ស្របនិងការចាប់ផ្តើមអាជីវកម្មរ៉ែមាសខ្នាតឧស្សាហកម្មតាមស្តង់ដាអន្តរជាតិជាលើកដំបូងនៅកម្ពុជា ប្រតិបត្តិការធនធានរ៉ែនៅតំបន់អូរខ្វាវនឹងបង្កើតបានជាគំរូនាំមុខដល់ការធ្វើអាជីវកម្មធនធានរ៉ែដទៃទៀត។

គម្រោងនេះ ទទួលបានសិទ្ធិអនុញ្ញាតបរិស្ថានពេញលេញពីក្រសួងបរិស្ថានកាលពីឆ្នាំ ២០១៧ និងអាជ្ញាប័ណ្ណរុករករ៉ែឧស្សាហកម្មជាបន្តបន្ទាប់ពីក្រសួងរ៉ែ និងថាមពល កាលពីឆ្នាំ ២០១៨។ បន្ទាប់មកគម្រោងនេះក៏បន្តទទួលបាននូវកិច្ចព្រមព្រៀងវិនិយោគរ៉ែកាលពីចុងឆ្នាំ ២០១៩ ពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៕

*ដោយ សេន ចន្ធូ*

*ប្រភព៖ postkhmer. ចេញផ្សាយថ្ងៃទី១៤ខែមិថុនា ឆ្នាំ២០២១*

## CDC អនុម័តគម្រោងវិនិយោគចំនួន៣ មានតម្លៃជិត១៥ លានដុល្លារ



*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ២០២១](), រូបភាព៖ ហុង មិនា*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)បានអនុម័តគម្រោងវិនិយោគរោងចក្រកាត់ដេរចំនួន៣ ដែលមានតម្លៃសរុបជិត១៥លានដុល្លារ និងបង្កើតការងារបានជាង៣ពាន់កន្លែង ។

សេចក្តីប្រកាសព័ត៌មានរបស់CDCបានឱ្យដឹងថា យោងតាមសំណើសុំវិនិយោគបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់របស់វិនិយោគគិន CDCសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរដល់ក្រុមហ៊ុនចំនួន៣ រួមមាន ៖ ទី១ ក្រុមហ៊ុន J.A.K Garment Co., Ltd មានទីតាំងស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានទុនវិនិយោគចំនួន២,៤លានដុល្លារ អាចបង្កើតការងារបាន ១ ០៥៣ កន្លែង, ទី២ ក្រុមហ៊ុន Premier Tech Garment (Cambodia) Co., Ltd ដែលស្ថិតនៅស្រុកបាទី ខេត្តតាកែវ មានទុនវិនិយោគចំនួន ៤,៣ លានដុល្លារ បង្កើតការងារបានចំនួន ១ ៧៤៨ កន្លែង និងទី៣ ក្រុមហ៊ុន Chanco Textiles (Cambodia) Co., Ltd: មានទីតាំងស្ថិតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានទុនវិនិយោគចំនួន ៨,២ លានដុល្លារ និងបង្កើតការងារបានចំនួន ៤២៤ កន្លែង។

លោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មបានលើកឡើងថា ទោះបីពិភពលោកកំពុងជួបនឹងវិបត្តសេដ្ឋកិច្ចដោយសារការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ក៏កម្ពុជា នៅតែទទួលបានការចូលមកបណ្តាក់ទុកជាបន្តបន្ទាប់ ដោយសារតែកម្ពុជាមានភាពអំណោយផលពីកត្តាភូមិសាស្ត្រ និងស្ថេរភាពនយោបាយ រួមទាំងកត្តាផ្សេងៗមួយចំនួនទៀតដូចជា បញ្ហាជម្លោះពាណិជ្ជកម្មរវាងចិន និងអាមេរិក កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ និងទ្វេភាគី ច្បាប់វិនិយោគអំណោយផលហេដ្ឋារចនាសម្ព័ន្ធល្អ និងបញ្ហានយោបាយនៅប្រទេសមីយ៉ាន់ម៉ា។

គួរបញ្ជាក់ផងថា ក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគចំនួន ២៣៨ គម្រោង ដែលមានទុនវិនិយោគសរុបចំនួន ៨,២ ប៊ីលានដុល្លារ ថយចុះ ១២%ធៀបនឹងឆ្នាំ២០១៩។ បើធៀបនឹងការព្យាកររបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) ការថយចុះនេះគឺស្ថិតក្នុងកម្រិតមួយល្អប្រសើរ៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ១៥ ខែមីថុនា ឆ្នាំ២០២១]()*

## ទីផ្សារជ័រកៅស៊ូនឹងអាចមានស្ថិរភាពល្អ ខណៈកម្ពុជាកំពុងទទួលបានឱកាសវិនិយោគរោងចក្រផលិតសំបកកង់រថយន្ត



*ប្រភព៖ CEN Cambodia Express News, 2021*

អ្នកធុរកិច្ចផ្ទើមកម្ពុជា បានរំពឹងថា ទីផ្សារជ័រកៅស៊ូ អាចមានស្ថិរភាពល្អ នឹងមានការដាំដុះដំណាំកៅស៊ូច្រើនជាងមុន ខណៈកម្ពុជាកំពុងទទួលបានឱកាសវិនិយោគរោងចក្រផលិតសម្បកកង់រថយន្ត ដែលនឹងត្រូវការជ័រកៅស៊ូច្រើនសម្រាប់ផ្គត់ផ្គង់។

លោកឧកញ៉ាលឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជាបានឱ្យដឹងថា គម្រោងវិនិយោគរោងចក្រផលិតសំបកកង់រថយន្តនៅកម្ពុជា នឹងផ្តល់ផលប្រយោជន៍ច្រើនដល់ផលិតកម្មកៅស៊ូក្នុងស្រុក បង្កើតការងារ និងបង្កើនចំណូលពន្ធជូនរដ្ឋផងដែរ។

លោកឧកញ៉ាបន្តថា ការដាំដុះកៅស៊ូ បច្ចុប្បន្នកម្ពុជាមានផ្ទៃដីដាំដុះកៅស៊ូប្រមាណ៤០ម៉ឺនហិកតា ហើយនៅក្នុងមួយឆ្នាំៗ កម្ពុជាបាននាំចេញកៅស៊ូជាច្រើនផងដែរ។ លោកបន្តថា ចំពោះគម្រោងដែលកម្ពុជាទទួលបានការវិនិយោគបង្កើតរោងចក្រសំបកកង់រថយន្តនេះ គឺជាផ្នែកមួយយ៉ាងសំខាន់ ដោយយើងរំពឹងថា ជ័រកៅស៊ូនៅកម្ពុជា នឹងមានទីផ្សារងើបឡើងវិញ ជាពិសេសរក្សាស្ថិរភាពតម្លៃល្អ។

គួរបញ្ជាក់ថា មានក្រុមហ៊ុនផលិតសំបកកង់រថយន្តធំៗមួយចំនួន បានប្រកាសចូលមកកាន់ទីផ្សារកម្ពុជា ក្នុងនោះ ក្រុមហ៊ុនJiangsu General Science Technology បានប្រកាសបោះទុនវិនិយោគ តម្លៃជាង ២០០លានដុល្លារ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដោយមានសមត្ថភាពផលិតសំបកកង់រថយន្តប្រមាណ៦លានសំបកក្នុងមួយឆ្នាំៗ។ លើសពីនេះមានក្រុមហ៊ុន Sailun Group នឹងពិចារណាបង្កើតរោងចក្រផលិតកង់រថយន្តដឹកអ្នកដំណើរនៅកម្ពុជា ក្នុងទុនវិនិយោគចំនួនប្រមាណ ១៨០ លានដុល្លារអាមេរិក នៅតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តស្វាយរៀង។ ក្រុមហ៊ុន "CART TIRE CO., LTD" បោះទុនវិនិយោគ បង្កើតរោងចក្រផលិតសំបកកង់យានយន្តនៅតំបន់សេដ្ឋកិច្ចពិសេសឃើលូ បាវិត ខេត្តស្វាយរៀង មានទុនវិនិយោគប្រមាណ ១៥ លានដុល្លារអាមេរិក និងអាចបង្កើតការងារបាន ចំនួន ៣៨០កន្លែង៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ cen-news.com ចេញផ្សាយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២១*

## កម្ពុជា នឹងបង្កើនការនាំចេញគ្រាប់ស្វាយចន្ទីកែច្នៃទៅកាន់ទីផ្សារអឺរ៉ុប អាមេរិក កាណាដា ចិន និងអូស្ត្រាលី



*ប្រភព៖ SWIFT NEWS, 2021*

បន្ទាប់ពីជោគជ័យក្នុងការនាំចេញគ្រាប់ស្វាយចន្ទីទៅប្រទេសជប៉ុន ក្រុមហ៊ុន Top Planning Japan (TPJ) បានរៀបចំទិសដៅអនាគត ដោយសហការជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី ជ័យ សំបូរ ដែលមានទីតាំងនៅភូមិត្រពាំងអារក្ស ឃុំជ័យ ស្រុកកំពង់ស្វាយ នឹងបង្កើនការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប សហរដ្ឋអាមេរិក កាណាដា ចិន និងអូស្ត្រាលី។

ទន្ទឹមនឹងនេះ ក្រុមហ៊ុនគ្រោងនឹងកសាងឃ្លាំងស្តុកគ្រាប់ស្វាយចន្ទីស្រស់ដែលអាចស្តុកទុកយ៉ាងតិច ៥ ០០០ តោន ដើម្បីធានាបរិមាណផ្គត់ផ្គង់។ លើសពីនេះទៀត នៅឆ្នាំ២០២៣ ក្រុមហ៊ុន TPJ គ្រោងបង្កើតរោងចក្រកែច្នៃ

ដែលមានសមត្ថភាពផលិតបានរហូតដល់២ ០០០ទៅ ៣ ០០០តោនក្នុងមួយឆ្នាំ។

យោងតាមរបាយការណ៍របស់នាយកដ្ឋាន កសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានឲ្យដឹងថា ក្រុមហ៊ុន Top Planning Japan (TPJ) បានទទួល គម្រោងគាំទ្រដើម្បីសិក្សាលំអិត អំពីស្ថានភាពទូទៅនៃ ខ្សែសង្វាក់តម្លៃស្វាយចន្ទី ដោយមានការគាំទ្រពីអង្គការ JICA ដើម្បីកសាងផែនការមេ សម្រាប់អភិវឌ្ឍ និងលើកកម្ពស់ ផលិតផលស្វាយចន្ទីកម្ពុជា ក្នុងខេត្តគោលដៅចំនួន៤ (ព្រះវិហារ កំពង់ធំ សៀមរាប និងកំពង់ចាម)។

ជាការសាកល្បងអនុវត្តគម្រោង ក្រុមហ៊ុន TPJ បានចុះ កិច្ចព្រមព្រៀង ជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី ជ័យសំបូរ ទិញគ្រាប់ស្វាយចន្ទីធ្វើការកែច្នៃសាកល្បង ប្រមាណចំនួន១៥០តោន តាមការចរចារតម្លៃលើប្រភេទ និងគុណភាព តាមទីផ្សារជាក់ស្តែង ប្រមាណ២០ម៉ឺន ដុល្លាក្នុងឆ្នាំ២០២០។ ឆ្នាំ២០២១នេះ សិប្បកម្មគ្រោងទិញ គ្រាប់ស្វាយចន្ទីចំនួន ១០០០តោនពីកសិករ ដែលក្នុង នោះ ក៏នឹងសាកល្បងកែច្នៃគ្រាប់ស្វាយចន្ទីសរីរាង្គ ចំនួន៣០តោន ដែលទទួលទិញពីសហគមន៍ផលិត គ្រាប់ស្វាយចន្ទីសរីរាង្គ ក្នុងខេត្តព្រះវិហារ។

កន្លងទៅ ក្រុមហ៊ុន TPJ បានចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី ជ័យសំបូរ លើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ដើម្បីសាងសង់ រោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីខ្នាតតូចជាការសាកល្បង ក្នុងការលើកកម្ពស់គុណភាពគ្រាប់ស្វាយចន្ទីស្រស់ និង ផ្តល់តម្លៃខ្ពស់ដល់កសិករក្នុងតំបន់ និងកសិករដែល បានចុះកិច្ចសន្យាផលិតកម្មកសិកម្ម ធានាគុណភាព និងសុវត្ថិភាពគ្រាប់ស្វាយចន្ទី។

ជាលទ្ធផល គ្រាប់ស្វាយចន្ទីកែច្នៃរួច បានបង្ហាញខ្លួន នៅលើទីផ្សារនៃប្រទេសជប៉ុននាពេលថ្មីៗនេះ ដែល លើកទី១មានចំនួន៧តោន និងលើកទី២ មានចំនួន ៩ តោន កំពុងត្រូវបានដាក់ចូលក្នុងទូកុងទីន័ររួចរាល់ ហើយគ្រោងនាំចេញ និងទៅដល់ទីក្រុង OSAKA នៅ ថ្ងៃទី១៥ ខែកក្កដា ខាងមុខនេះ។

សិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី ជ័យសំបូរ គ្រោងនាំចេញ ផលិតផលរបស់ខ្លួនក្នុងបរិមាណចំនួន ៩តោនជា រៀងរាល់ខែ ហើយអាចនឹងកើនឡើងទៅតាមការបញ្ជាទិញ ពីទីផ្សារជប៉ុននាពេលអនាគត៕ *ដោយ ម៉ែន ខែមរៈ*

*<u>ប្រភព៖</u> SWIFT NEWS ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែមេសា ក្នុងឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែមេសាឆ្នាំ២០២១នេះ រដ្ឋបាល ថ្នាក់ជាតិ ប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស បានសរុប ១០៦,៧ប៊ីលានរៀល ដែលមានការធ្លាក់ចុះ ប្រមាណជា ៥៥,៣% ធៀបនឹងខែមីនា។ ការធ្លាក់ចុះ ចំណូលនេះ ដោយសារតែការថមថយសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍រីករាលដាលជំងឺកូវីដ-១៩នៅទូទាំង ពិភពលោក។ ជាពិសេសព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ បាននឹងកំពុងដាក់សម្ពាធដល់ការសម្រេចគោលដៅ ប្រមូលចំណូលឆ្នាំ២០២១ ផងដែរ។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូល បានប្រមាណជា ១០៣,៥៦ប៊ីលានរៀល នៅក្នុងខែមេសា ឆ្នាំ២០២១នេះ ដែលបានធ្លាក់ចុះប្រហែលជា៥៥,៧% ធៀបនឹងខែមីនា។

ស្របពេលនោះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញ មានចំនួន ៣,១២ប៊ីលានរៀលនៅក្នុងខែមេសា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៣៦,៦% ធៀបនឹងខែមីនា៕

*ដោយៈ មិត្ត ចន្ធី*

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា |
|---|---|---|---|---|
| ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 159.5 | 153.1 | 238.5 | 106.7 |
| កំណើន(%) | | -4.0% | 55.8% | -55.3% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.6 | 103.56 |
| កំណើន(%) | | -3.9% | 54.9% | -55.7% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 |
| កំណើន(%) | | -11.0% | 109.4% | -36.6% |

*ប្រភព៖តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែមេសាឆ្នាំ២០២១ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកលើមុខទំនិញនៅក្នុងខែមេសា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែមេសា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា ជាមួយសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណជា ៦៨៥,៧លានដុល្លារ ដែលមានការធ្លាក់ចុះប្រមាណជា ១២,៣% បើធៀបនឹងខែមីនា។

ជាក់ស្តែង នៅក្នុងខែមេសា ឆ្នាំ២០២១ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណជា ៦៥៦,៣លានដុល្លារ ដែលមានការធ្លាក់ចុះប្រហែល ១១,៧% បើធៀបនឹងខែមីនា។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញសម្រាប់ធ្វើដំណើរ (ដូចជាការបូបយួរ ការបូបដាក់លុយ និងគ្រឿងអលង្ការ) សំលៀកបំពាក់ ស្បែកជើង និងផលតផលផ្សេងៗទៀត។

ស្របពេលនោះដែរ ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់២៩,៤លានដុល្លារ នៅក្នុងខែមេសា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២៤,៨% បើធៀបនឹងខែមីនា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន ៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់យានយន្ត ប្រេងសណ្តែក(soybean oilcake) និងផលិតផលផ្សេងៗទៀត។

*ដោយ មិត្ត ចន្ធី*

| បរិយាយ (គិតជាលានដុល្លារ) | មករា | កុម្ភៈ | មីនា | មេសា |
|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | 614.5 | 572.7 | 782.1 | 685.7 |
| កំណើន % | | -6.8% | 36.6% | -12.3% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 |
| កំណើន % | | -1.8% | 17.4% | -24.8% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 |
| កំណើន % | | -7.1% | 37.7% | -11.7% |

*ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យពាណិជ្ជកម្មសហរដ្ឋអាមេរិក*

# ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ថវិកាសារពើពន្ធរយៈពេលមធ្យមរបស់ប្រទេសហ្វីលីពីន ឆ្នាំ២០២១-២០២៤

គណកម្មាធិការអភិវឌ្ឍន៍សម្របសម្រួលថវិកាDevelopment Budget Coordination Committee (DBCC) របស់ហ្វីលីពីន បានធ្វើការត្រួតពិនិត្យឡើងវិញពីការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម សម្រាប់ឆ្នាំសារពើពន្ធ ២០២១ ដល់ ២០២៤។

ក្នុងតារាងខាងក្រោម DBCC បានរំពឹងថាការប្រមូលចំណូលសម្រាប់ឆ្នាំសារពើពន្ធ ២០២១ មានចំនួន PH២ ៨៨១,៥ប៊ីលានឬស្មើនឹង១៤,៥% នៃ ផ.ស.ស នឹងកើនឡើងដល់ PH៣ ២៨៩,៥ប៊ីលានក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ ខណៈពេលដែលសកម្មភាពសេដ្ឋកិច្ចនៅក្នុងរយៈពេលមធ្យមមានការកើនឡើង គេរំពឹងថាការប្រមូលចំណូលអាចនឹងកើនឡើងដល់ PH៣ ៩៩៩,៣ ប៊ីលានក្នុងឆ្នាំ ២០២៤។

ចំណែកឯការចំណាយ ដែលត្រូវបានប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០២១នេះមានរហូតដល់ PH៤ ៧៣៧,១ ប៊ីលាន ដោយសារមានតម្រូវការថវិកាដើម្បីគាំទ្រកម្មវិធី (Bayanihan II) ជំហានទី២ រួមបញ្ចូលទាំងថ្នាំបង្ការកូវីដ-១៩ផងដែរ។

ការចំណាយត្រូវបានគេប៉ាន់ប្រមាណថា ក្នុងចន្លោះឆ្នាំ ២០២២ ដល់ឆ្នាំ២០២៤ នឹងមានការកើនឡើងជាបន្តបន្ទាប់រហូតដល់ PH៥ ៤០៣,៦ប៊ីលាន នៅឆ្នាំ២០២៤។ ចំណាយថវិកានេះមានការកើនឡើងតាមរយៈកំណើនមូលនិធិសមធម៌ Growth Equity Fund (GEF) ក្នុងគោលបំណងជួយអង្គភាពរដ្ឋាភិបាលមូលដ្ឋាន Local Government Units (LGUs) ដែលក្រីក្រក្នុងការដោះស្រាយបញ្ហានៃការបាត់បង់ឱកាសការអភិវឌ្ឍមិនស្មើភាពគ្នា និងមានអត្រានៃភាពក្រីក្រខ្ពស់។

សម្រាប់ឆ្នាំ២០២១ ប្រទេសហ្វីលីពីន នឹងមានឱនភាពថវិកាប្រមាណ ៩,៣%នៃ ផ.ស.ស និង ប្រមាណ ៧,៥% នៃ ផ.ស.ស ក្នុងឆ្នាំ២០២២។ បន្ថែមពីនេះ DBCC រំពឹងថាឱនភាពថវិកានឹងមានត្រឹម៦,៣% និង ៥,៣% សម្រាប់ឆ្នាំ២០២៣ និង២០២៤រៀងគ្នា។

**តារាងថវិកាសារពើពន្ធហ្វីលីពីន រយៈពេលមធ្យម (២០២១-២០២៤) (គិតជាប៊ីលានប៉េសូ Pesos, PH)**

| បរិយាយ | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|
| | ជាក់ស្តែង | ផែនការ | ប៉ាន់ស្មាន | | |
| ចំណូល | 2,856.0 | 2,881.5 | 3,289.5 | 3,586.4 | 3,999.3 |
| % នៃ ផសស | 15.9% | 14.5% | 14.9% | 14.8% | 15.1% |
| ចំណាយ | 4,227.4 | 4,737.1 | 4,954.6 | 5,114.5 | 5,403.6 |
| % នៃ ផសស | 23.6% | 23.9% | 22.4% | 21.1% | 20.3% |
| អតិរេក/ឱនភាព | (1,371.4) | (1,855.6) | (1,665.1) | (1,528.1) | (1,404.3) |
| % នៃ ផសស | -7.6% | -9.3% | -7.5% | -6.3% | -5.3% |

*ប្រភព៖ Development Budget Coordination Committee (DBCC)*

## ទំនាក់ទំនងរវាងអាស៊ាន និងចិន លើកកម្ពស់គុណតម្លៃអាស៊ី




*ក្បួនដង្ហែនៃទាហានជើងទឹកចិននៅក្នុងពិធីបើកសមយុទ្ធសមុទ្រចិន-អាស៊ាន នៅកំពង់ផែយោធាហ្សេនជាំង ខេត្តក្វាងទុង ភាគខាងត្បូងប្រទេសចិន កាលពីខែតុលាឆ្នាំ ២០១៨។ រូបថត៖ Bangkok Post*

គិតមកដល់ពេលនេះ ទំនាក់ទំនង និងភាពជាដៃគូយុទ្ធសាស្ត្ររវាងអាស៊ាន និងចិនដើម្បីអនាគតរួមគ្នា មានរយៈពេលជិត៣០ឆ្នាំហើយ។ ក្រៅពីផ្តោតលើកិច្ចសហប្រតិបត្តិការ និងការកសាងគម្រោងមួយចំនួនរួមគ្នា អាស៊ានរំពឹងថា ខ្លួននឹងមានឱកាសជាច្រើនទៀតដើម្បីសហការជាមួយចិន ដើម្បីបង្កើនគុណតម្លៃអាស៊ីថែមមួយកម្រិតទៀតក្រោយវិបត្តិកូវីដ១៩។ រដ្ឋមន្ត្រីការបរទេសរបស់ចិន លោក Wang Yi បានមានប្រសាសន៍នៅក្នុងពិធីបើកកិច្ចប្រជុំចុងឈីញ (Chongqing) កាលពីសប្តាហ៍មុន យ៉ាងដូច្នេះថា បន្ទាប់ពីវិបត្តិកូវីដ១៩ កន្លងផុតទៅ ចិននឹងបើកទីផ្សារ និងផ្តល់ឱកាសជាច្រើនបន្ថែមទៀតដល់សមាជិកអាស៊ាន និងប្រទេសដទៃទៀត។

គួររំលឹកថា កាលពីបីទសវត្សន៍មុន ទំហំពាណិជ្ជកម្មរវាងអាស៊ាន និងចិន មានតិចជាង ៨ប៊ីលានដុល្លារសហរដ្ឋអាមេរិក។ ប៉ុន្តែបច្ចុប្បន្នអាស៊ានបានប្រែក្លាយខ្លួនទៅជាដៃគូពាណិជ្ជកម្មធំបំផុតរបស់ចិនជំនួសឱ្យសហគមន៍អឺរ៉ុប។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០ ទំហំពាណិជ្ជកម្មរបស់ចិនជាមួយអាស៊ាន បានកើនឡើងរហូតដល់ទៅ ៦៨៤,៦ប៊ីលានដុល្លារសហរដ្ឋអាមេរិក។ លើសពីនោះ នៅក្នុងឆ្នាំ២០១៩ មុនពេលមានវិបត្តិកូវីដ១៩ ការហោះហើរទៅមករវាងប្រជាជនចិន និងអាស៊ីអាគ្នេយ៍ក្នុងមួយសប្តាហ៍មានចំនួនប្រហែលជា ៤ ៥០០លើក។ ទន្ទឹមនឹងនេះ ចិនក៏បានបង្កើតគម្រោងផ្លូវមួយខ្សែក្រវ៉ាត់មួយ ដើម្បីតភ្ជាប់ផ្លូវគោកជាមួយបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍។ រីឯអាស៊ានវិញ បានផ្តួចផ្តើមបង្កើតគម្រោងចំនួន៣០ ដើម្បីឱ្យចិនពិចារណា ដែលគម្រោងទាំងនោះគ្របដណ្តប់លើ៖ ការប្រយុទ្ធប្រឆាំងកូវីដ១៩ ការស្តារសេដ្ឋកិច្ច ការតភ្ជាប់ ការផ្តល់ជំនួយ និងការការពារគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចិរភាព។ ជារួមអាស៊ានមានការរំពឹងទុកខ្ពស់ថា ចិននឹងផ្តល់ការឆ្លើយតបវិជ្ជមានចំពោះសំណើរបស់ខ្លួន។ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ Bangkok Post ចេញផ្សាយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១*

## វៀតណាមកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយថ្មីដើម្បីលើកទឹកចិត្តដល់ការវិនិយោគលើវិស័យកសិកម្ម



*ប្រភព៖ Viet Nam News, 2021 រូបថត៖ VNA/VNS Photo*

ក្រសួងផែនការ និងវិនិយោគ របស់វៀតណាមកំពុងតែរៀបចំក្រឹត្យមួយ គាំទ្រដល់ការអភិវឌ្ឍការវិនិយោគរបស់សហគ្រាសក្នុងវិស័យកសិកម្ម និងតំបន់ជនបទដើម្បីទាក់ទាញការវិនិយោគបន្ថែម។ គោលនយោបាយថ្មីដែលគ្រោងនឹងបង្កើតនេះមានគោលបំណង៖ ទី១-ដើម្បីជំរុញការនាំចេញផលិតផលកសិកម្ម ទៅកាន់សហគមន៍អឺរ៉ុប ព្រោះប្រទេសវៀតណាមបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហគមន៍អឺរ៉ុប (EU-Viet Nam Free Trade Agreement) រួចហើយ ទី២-ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលកំពុងតែចោទឡើង នៅក្នុងផលិតកម្មកសិកម្ម និងទី៣-ដើម្បីដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីវិបត្តិកូវីដ១៩។

យោងតាមខ្លឹមសារ ដែលមានចែងនៅក្នុងសេចក្តីព្រាងនៃក្រឹត្យនោះ ចំណាយវិនិយោគមូលធនលើវិស័យកសិ-ឧស្សាហកម្មរបស់វៀតណាមចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ មានទំហំប្រមាណជា ១០៧ទ្រីលានដុង ស្មើនឹង ៤,៦ប៊ីលានដុល្លារ។ នៅក្នុងនោះរដ្ឋាភិបាលគ្រោងចំណាយទឹកប្រាក់ប្រមាណជា ៨,៦ទ្រីលានដុង ដើម្បីអនុវត្តគម្រោងចំនួន ៨០០គម្រោង។ ក្រសួងផែនការ និងវិនិយោគរបស់វៀតណាមបានព្យាករណ៍ថា ប្រសិនបើសហគ្រាស ដែលវិនិយោគលើវិស័យកសិកម្មចំនួន ១០០សហគ្រាស និងមានមូលធនវិនិយោគ ចំនួន ១០០ប៊ីលានដុងក្នុង០១សហគ្រាស ត្រូវបានបង្កើតឡើងរៀងរាល់ឆ្នាំ វានឹងអាចបង្កើតការងារផ្ទាល់ជូនប្រជាពលរដ្ឋបានចំនួន ១០ ០០០កន្លែង និងការងារដោយប្រយោលចំនួន ៣០ ០០០កន្លែង៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ Vietnam News ចេញផ្សាយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១*

## កម្ពុជារំពឹងថានឹងចរចាជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) ឆាប់ៗនេះ



លោក ប៉ែន សុវិជាតិ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងកិច្ចប្រជុំនាពេលកន្លងទៅ។ រូបថត ក្រសួងពាណិជ្ជកម្ម

សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) ជាសហព័ន្ធសេដ្ឋកិច្ចតំណាងឱ្យប្រទេសចំនួន ៥ រួមមានរុស្ស៊ី អាមេនីកាហ្សាក់ស្ថាន បេឡារុស និងកៀហ្ស៊ីស៊ីស្ថាន ដែលមានប្រជាជនសរុបជាង ១៨៤ លាននាក់ក្នុងឆ្នាំ ២០២០ និងមានផលិតផលក្នុងស្រុក GDP សរុបរួមគ្នា ៤,៧៧ ពាន់ពាន់លានដុល្លារ។

កម្ពុជា និងEAEU កំពុងធ្វើការយ៉ាងសកម្ម ដើម្បីជំរុញការចាប់ផ្តើមចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-EAEU ឱ្យបានឆាប់តាមដែលអាចធ្វើបាន នេះបើយោងតាមឯកឧត្តម ប៉ែន សុវិជាតិ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។

លោកបានបន្តទៀតថា ក្នុងចំណោម៥ ប្រទេសដែលជាសមាជិកនៃ EAEU មាន៤ ប្រទេសហើយ ដែលគាំទ្រឱ្យមានកិច្ចចរចាពាណិជ្ជកម្មសេរីជាមួយកម្ពុជា ដែលក្នុងនោះក៏មានសហព័ន្ធរុស្ស៊ី ដែលជាប្រទេសធំនាំមុខក្នុង EAEU ជួយជំរុញសម្របសម្រួលឱ្យកិច្ចការនេះអាចប្រព្រឹត្តទៅតាមការរំពឹងទុក។

កម្ពុជានឹងទទួលបានផលចំណេញជាច្រើន ពីទំនាក់ទំនងទ្វេភាគីនេះ ទាំងការបើកច្រកទីផ្សារបន្ថែមទៀត ការទទួលបានការវិនិយោគពីបណ្តាប្រទេសទាំង៥ ព្រមទាំងការទទួលបានបច្ចេកវិទ្យាថ្មីៗ និងសហប្រតិបត្តិការវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច យោងតាមការថ្លែងរបស់ឯកឧត្តម ប៉ែន សុវិជាតិ។

ថ្មីៗនេះ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសតួកគី បានជួបជាមួយឯកអគ្គរដ្ឋទូតកៀហ្ស៊ីស៊ីស្ថានប្រចាំនៅប្រទេសតួកគី ដើម្បីជជែកពិភាក្សាគ្នាអំពីទស្សនវិស័យសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរួមទាំងក្នុង**ក្របខ័ណ្ឌ**នៃសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ព្រមទាំងអំពីលទ្ធភាពនៃការពិចារណា លើកិច្ចព្រមព្រៀងដាច់ដោយឡែករវាងកម្ពុជា និងកៀហ្ស៊ីស៊ីស្ថាន លើវិស័យពាណិជ្ជកម្មសេរីពន្ធគ្រួតស៊ីគ្នា និងតំបន់មិនត្រូវការទិដ្ឋាការ។

អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា លោក ហុង វណ្ណៈ បានលើកឡើងថា កាហ្សាក់ស្ថាន គឺជាសមាជិក ដែលមានសក្តានុពលសេដ្ឋកិច្ចខ្លាំងនៅអឺរ៉ុបខាងកើត ហើយការពិភាក្សារបស់

ភាគីទាំង២ខាងលើនេះ គឺចង់ដឹងឱ្យបានច្បាស់នូវប្រភេទទំនិញដែលអាចដោះដូរជាមួយគ្នាបាន ដើម្បីងាយសម្រួចទៅលើផលិតផលក្នុងស្រុកក្នុងការជំរុញផលិតកម្មឱ្យស្របទៅតាមតម្រូវការប្រទេសដៃគូ។

យោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្ម ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងEAEU ក្នុងឆ្នាំ២០២០ មានតម្លៃសរុប ៦៧,៣៧ លានដុល្លារកើនឡើង ១៨,២២%ធៀបនឹងឆ្នាំ២០១៩។ ក្នុងនោះការនាំចេញរបស់កម្ពុជាមានតម្លៃ ៥២,១៩ លានដុល្លារ កើន ០,៧៣% និងការនាំចូលវិញពី EAEU មានតម្លៃ ១៥,១៨ លានដុល្លារ កើនឡើង ១៩៣,៥៧%។

ផលិតផលដែលកម្ពុជានាំចេញទៅ EAEU មានភាគច្រើនជាផលិតផលកសិកម្ម និងវាយនភណ្ឌ ខណៈផលិតផលដែល EAEU នាំមកកម្ពុជារួមមាន គ្រឿងម៉ាស៊ីន ត្រាក់ទ័រ និងគ្រឿងបន្លាស់យានយន្តកសិកម្ម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ធនាគារសហព័ន្ធអាមេរិក នឹងនៅតែរក្សាជំហរលើគោលនយោបាយរបស់ខ្លួន ថ្វីបើមានកំណើនអតិផរណា



*ប្រភព៖ AFP ២០២១*

ធនាគារសហព័ន្ធអាមេរិក(US Federal Reserve) ទំនងជាមិនផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុរបស់ខ្លួននោះឡើយ ទោះបីជាអត្រាអតិផរណាមានការកើនឡើង និងភាពខ្វះខាតនៃវឌ្ឍនភាពក្នុងការស្តារឡើងវិញនៃការងារដែលបាត់បង់កំឡុងវិបត្តិជំងឺកូវីដ-១៩។ លោក Jerome Powell ទេសាភិបាលធនាគារសហព័ន្ធ បានលើកឡើងថា ធនាគារសហព័ន្ធនឹងបន្តកម្មវិធីទិញសញ្ញាបណ្ណដ៏ធំសម្បើម និងអត្រាការប្រាក់កម្ចីទាបបំផុតរបស់ខ្លួន ដរាបណាទិន្នន័យលើចំនួនអ្នកមានការងារធ្វើនៅគ្រប់ស្រទាប់/ក្រុម មានភាពល្អប្រសើរឡើងវិញជាប់ជាបន្ត។

ថ្វីបើមានការកើនឡើងនៃអតិផរណានាពេលថ្មីៗនេះ មន្ត្រីធនាគារសហព័ន្ធ បានធ្វើការធានាឡើងវិញជាថ្មីថា ការកើនឡើងនេះគឺជាស្ថានការបញ្ចាបណ្តោះអាសន្នប៉ុណ្ណោះ ដែលភាគច្រើនបណ្តាលមកពីការកើនឡើងនៃតម្លៃឡានប្រើប្រាស់រួច(Used Car)។

ទន្ទឹមនេះ អ្នកសេដ្ឋកិច្ច លោក Joel Naroff បានលើកឡើងក្នុងការវិភាគមួយថា គុណសម្បត្តិនៃការបើក

សេដ្ឋកិច្ចឡើងវិញ គឺការធ្វើឱ្យកំណើនសេដ្ឋកិច្ចមានការកើនឡើងលឿន ប៉ុន្តែគុណវិបត្តិ គឺអតិផរណាសម្រាប់អ្នកប្រើប្រាស់ ក៏កើនឡើងភ្លាមៗដែរ ហើយបញ្ហាកម្លាំងពលកម្ម នឹងដាក់សម្ពាធលើអាជីវកម្ម។

ជាក់ស្តែង សន្ទស្សន៍តម្លៃសម្រាប់អ្នកប្រើប្រាស់ នៅក្នុងខែឧសភា បានកើនឡើង ៥% បើធៀបនឹងខែឧសភាឆ្នាំមុន។ ដោយឡែក អត្រាអ្នកគ្មានការងារធ្វើសរុបបានធ្លាក់ចុះទៅត្រឹម ៥,៨% នៅក្នុងខែឧសភា ក៏ប៉ុន្តែអត្រាគ្មានការងារធ្វើសម្រាប់ជនជាតិអាមេរិកស្បែកខ្មៅ នៅតែខ្ពស់ ក្នុងអត្រា ៩,១% ហើយការងារដែលបានបាត់បង់ក្នុងកំឡុងវិបត្តិជំងឺរាតត្បាត ដែលមានប្រមាណច្រើនជាង ៧លានការងារ នៅតែមិនទាន់ស្តារបានឡើងវិញនោះឡើយ៕ ***ដោយ ជា សិរីរតន៍***

*ប្រភព៖ Khmer Times ចេញផ្សាយ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២១*

## សេដ្ឋកិច្ចបារាំង នឹងមានកំណើនខ្ពស់ជាងការរំពឹងទុកនៅឆ្នាំ២០២១




*ប្រភព៖ ធនាគារជាតិបារាំង ២០២១*

យោងតាមធនាគារជាតិបារាំង ដែលបានលើកឡើងកាលពីថ្ងៃទី១៤ ខែមិថុនានេះ បង្ហាញថា សេដ្ឋកិច្ចបារាំងនៅឆ្នាំ២០២១ នឹងអាចងើបឡើងវិញលឿនជាងការរំពឹងទុកពីមុន។ ក្នុងនោះដែរ នៅក្នុងទស្សនវិស័យសេដ្ឋកិច្ចប្រចាំត្រីមាសរបស់ខ្លួន ធនាគារជាតិបារាំង បានបង្កើនការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចរបស់ខ្លួនចំនួន ០,៤ ពិន្ទុភាគរយ ដែលនាំឱ្យការព្យាករណ៍កំណើនសេដ្ឋកិច្ចឆ្នាំ២០២១ មានអត្រា ៥,៨% ដែលខ្ពស់ជាងមធ្យមភាគនៃកំណើនសេដ្ឋកិច្ចក្នុងតំបន់អឺរ៉ុបទាំងមូល ដែលត្រូវបានព្យាករណ៍ត្រឹមអត្រា ៤,៦%។

សម្រាប់ឆ្នាំ២០២២វិញ សេដ្ឋកិច្ចបារាំងត្រូវបានព្យាករណ៍ថា នឹងមានកំណើន ៤%បើធៀបជាមួយនឹងការព្យាករណ៍កាលពីខែមីនា ដែលមានអត្រាត្រឹម ៣,៨%។ កំណើននេះបានឆ្លុះបញ្ចាំងថា បារាំងនឹងអាចវិលត្រលប់ទៅរកទំហំសេដ្ឋកិច្ចមុនវិបត្តិវិញ នៅដើមឆ្នាំ២០២២។ ចំណែកឯ រដ្ឋាភិបាលបារាំងរំពឹងថា សេដ្ឋកិច្ចនឹងមានកំណើន ៥% នៅឆ្នាំ២០២១នេះ។

គួរបញ្ជាក់ផងដែរ សេដ្ឋកិច្ចបារាំង បានធ្លាក់ចុះ ៨% នៅឆ្នាំ២០២០ ដែលជាការធ្លាក់ចុះអាក្រក់បំផុត បើគិតចាប់តាំងពីសង្គ្រាមលោកលើកទី២មក៕
***ដោយ ជា សិរីរតន៍***
*ប្រភព៖ Xinhua ចេញផ្សាយ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១*

## លោក ពូទីន រំពឹងថា ពាណិជ្ជកម្មចិន-រុស្ស៊ី នឹងកើនដល់ ២០០ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២៤



*ប្រភព៖ SWIFT NEWS 2021*

ប្រធានាធិបតីរុស្ស៊ីលោក វ្លាឌីមៀ ពូទីន បាននិយាយថា «ទំនាក់ទំនងរុស្ស៊ី-ចិន បានឈានដល់កម្រិតមួយដែល

មិនធ្លាប់មានពីមុនមក» លោកបានបន្តថាភាគីទាំងពីរ រំពឹងថា នឹងជំរុញពាណិជ្ជកម្មទ្វេភាគីដល់ ២០០ប៊ីលាន ដុល្លារនៅឆ្នាំ២០២៤ ដោយប្រទេសទាំងពីរអាចរក្សា ពាណិជ្ជកម្មទ្វេភាគីនៅកម្រិតខាងលើ បានជាង ១០០ ប៊ីលានដុល្លារ ក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា ជាពិសេសនៅឆ្នាំ២០២០ ទោះបីមានផលប៉ះពាល់ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩ក៏ដោយ។ លោកបានបន្តទៀតថា ប្រទេសរុស្ស៊ី និងប្រទេសចិន កំពុងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ លើវិស័យជាច្រើន ដូចជាការផលិតយន្តហោះ ការស្រាវជ្រាវតាមច័ន្ទគតិ ថាមពលការពារបរិស្ថាន និងសហភាពសេដ្ឋកិច្ចជាមួយនឹងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ។ លោកបន្តថា រុស្ស៊ី និងចិន នឹងពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរបស់ពួកគេ នៅក្នុងសហគមន៍អន្តរជាតិ និងការពារផលប្រយោជន៍រួម ដោយកត់សម្គាល់ថា ការសម្របសម្រួលយុទ្ធសាស្ត្ររុស្ស៊ី-ចិនពិតជាមានអំណោយផលដល់ស្ថេរភាពយុទ្ធសាស្ត្រអន្តរជាតិ។

ប្រទេសរុស្ស៊ី និងចិន មានផលប្រយោជន៍រួមដែលជាគ្រឹះដ៏សំខាន់ នៃកិច្ចសហប្រតិបត្តិការទ្វេភាគីស៊ីជម្រៅ ហើយរុស្ស៊ីមានឆន្ទៈបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន។

គួរបញ្ជាក់ផងដែរថា ទំហំពាណិជ្ជកម្មទ្វេភាគីរវាងចិន និងរុស្ស៊ីបានកើនឡើងដល់ ៤០ប៊ីលានដុល្លារ ក្នុងរយៈពេល៤ខែដំបូងនៃឆ្នាំនេះ គឺកើនឡើង ១៩,៨%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។*ដោយ ម៉ែន ខែមរៈ* [*ប្រភព៖ SWIFT NEWS ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១*]

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

### ថ្ងៃចន្ទ ទី២១ ខែមិថុនា ឆ្នាំ២០២១

- កំណើនការលក់រាយនៅអូស្ត្រាលី ក្នុងខែមេសា ឆ្នាំ ២០២១
- ការធ្លាក់ចុះ អត្រាអ្នកអត់ការងារធ្វើរបស់រុស្ស៊ី នៅក្នុងខែមេសាឆ្នាំ ២០២១

### ថ្ងៃអង្គារ ទី២២ ខែមិថុនា ឆ្នាំ២០២១

- កំណើនសេដ្ឋកិច្ចរុស្ស៊ី កាលពីខែមេសាឆ្នាំ ២០២១
- សូចនាករនៃការធ្លាក់ចុះ ទំនុកចិត្តអតិថិជនរបស់ក្នុងខែឧសភាឆ្នាំ ២០២១

### ថ្ងៃពុធ ទី២៣ ខែមិថុនា ឆ្នាំ២០២១

- កំណើនសន្និធិប្រេងសាំងអាមេរិក នៅសប្តាហ៍ទី ៤ ខែមិថុនា
- កំណើនការវិនិយោគភាគហ៊ុនដោយជនបរទេសនៅក្នុងប្រទេសជប៉ុន ក្នុងមួយសប្តាហ៍ គិតត្រឹមថ្ងៃទី៥ ខែមិថុនាឆ្នាំ ២០២១

### ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមិថុនា ឆ្នាំ២០២១

- កំណើនទំនុកចិត្តអ្នកប្រើប្រាស់នៅកូរ៉េខាងត្បូង ក្នុងខែឧសភា ឆ្នាំ ២០២១
- កំណើននៃផលិតកម្មអាកាសធាតុ (The manufacturing climate)នៅប្រទេសបារាំង ក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២៥ ខែមិថុនា ឆ្នាំ២០២១

- កំណើនប្រាក់កម្ចីដល់ក្រុមគ្រួសារនៅតំបន់ចាយប្រាក់អឺរ៉ូ នៅក្នុងខែមេសាឆ្នាំ ២០២១
- ការថយចុះនៃប្រាក់ចំណូលផ្ទាល់ខ្លួន (Personal income)នៅសហរដ្ឋអាមេរិក ក្នុងខែមេសាឆ្នាំ ២០២១៕